

តើលោកអ្នកដឹងទេថា លោកអ្នកមានតម្លៃប៉ុណ្ណា?



អស់រយៈពេលជាងហាសិបឆ្នាំមកហើយ
ខ្ញុំបានព្យាយាមជួយមនុស្សជាច្រើនដែលមានបញ្ហាផ្សេងៗក្នុងជីវិតរបស់ពួកគេ ។ នៅទីបំផុត ខ្ញុំបានឈានដល់ការសន្និដ្ឋានមួយថា៖ បញ្ហាជាមូលដ្ឋាននៅក្នុងជីវិតរបស់មនុស្សនោះគឺ យើងមិនដឹងថា
ខ្លួនយើងមានតម្លៃប៉ុណ្ណា? ដូច្នេះហើយ
បានជាយើងបានប្រព្រឹត្តកំហុសដ៏ខ្លោចផ្សាបំផុត។

យើងជាអ្នកស្នងមរតកស្របច្បាប់ ច្រើនឥតគណនា ប៉ុន្តែផ្ទុយទៅវិញ
យើងលក់មរតករបស់យើងទាំងអស់
មកដូរយកអ្វីដែលគ្មានតម្លៃអាចប្រៀបផ្ទឹមបាន៖
មើលរូបអាសអាភាស ប្រើប្រាស់គ្រឿងញៀន ប្រមឹក សម្ភារៈនិយមបន្លំឯកសារហិរញ្ញវត្ថុជាដើម។

ដោយស្វែងរកមុខ អ្នកខ្លះអាចឲ្យតម្លៃខ្លួនគេខ្ពស់ជាង
តំណែងដ៏មានកិត្យានុភាពនៅក្នុងឆាកនយោបាយ ពិភពកម្សាន្ត
ឬសូម្បីតែនៅក្នុងវិស័យសាសនា ។ ប៉ុន្តែ សម្រាប់កិត្យានុភាពទាំងអស់ដែលពិភពលោកផ្តល់ឲ្យ វាមិនអាចប្រៀបធៀបនឹងតម្លៃនៃមរតករបស់យើង
ដែលមនុស្សមួយចំនួនបានដោះដូរដើម្បីជាថ្នូរនឹងកិត្យានុភាពនោះទេ ។

ប្រសិនបើយើង ចង់ដឹងតម្លៃដ៏ពិតរបស់យើងក្នុងនាមជាមនុស្ស
យើងត្រូវតែពិចារណាអំពីវិធីដ៏ពិសេស និងអស្ចារ្យដែលអ័ដាម
ជាបុព្វបុរសនៃពូជសាសន៍យើង ត្រូវបានបង្កើតឡើង ។

This teaching series, *Our Value, Our Worth*, explores how precious we are to God.

ការអស្ចារ្យនៃការបង្កើតលោកអ័ដាម

នៅក្នុងគម្ពីរយ៉ូហាន ១:១-២ យើងរកឃើញថា
អង្គព្រះពិតប្រាកដនៅក្នុងការបង្កើតមិនមែនជាព្រះជាព្រះវរបិតាទេ
ប៉ុន្តែគឺជាព្រះបន្ទូល ដែលបានគង់នៅជាមួយព្រះជាម្ចាស់
តាំងពីអស់កល្បជានិច្ច គឺជាបុគ្គលមួយអង្គ
ដែលក្រោយមកបានបង្ហាញយ៉ាងច្បាស់ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិថាជា ព្រះយេស៊ូវមកពីភូមិណាព្រះ

> សារ៉ែត៖
> «គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់បន្ទូល]
> ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន
> នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ» (យ៉ូហាន

9:3)។

គ្រប់
របស់ទាំងអស់ត្រូវបានបង្កើតឡើងដោយសារព្រះបន្ទូលរបស់ព្រះ៖« យើងរាល់គ្នាក៏យល់ដោយសារសេចក្តីជំនឿនោះថា
លោកីយបានកើតមក ដោយសារបន្ទូលនៃព្រះ" (ហេព្រើរ ១១:៣)។
«ដ្បិតទ្រង់គ្រាន់តែមានបន្ទូល នោះក៏កើតមានដូច្នោះ
ទ្រង់បានបង្គាប់នោះក៏មាននៅ» (ទំនុកតម្កើង ៣៣:៩)។
ប៉ុន្តែចំពោះកំណើតលោកអ័ដាមវិញមានចែងយ៉ាងច្បាស់នៅក្នុងគម្ពីរ
លោកុប្បត្តិ ២:៧ថា៖

> ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស
> ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ
> នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង។ (មានន័យថា
> មានជីវិតរស់ឡើង) ។»

ចូរស្រមៃមើលពីទិដ្ឋភាពនេះ! ព្រះអម្ចាស់បានលុតជង្គង់ចុះ
ហើយយកធូលីដីដាក់ក្នុងព្រះហស្តទ្រង់
រួចលាយជាមួយនឹងទឹកនិងសូនវាឲ្យក្លាយទៅជារាងកាយរបស់បុរស
ម្នាក់។ នេះគឺជារូបចម្លាក់ដ៏ល្អឥតខ្ចោះជាងគេ
ដែលមិនធ្លាប់មានជាងណាបានធ្លាក់ពីមុនមកទេ
ហើយវាពិតជាល្អឥតខ្ចោះជាងស្នាដៃធ្លាក់រូបរបស់លោកម៉ៃយេលេន
ហ្គឺឡូ (Michelangelo) ទៅទៀត។ ប៉ុន្តែ
រូបចម្លាក់នោះមិនទាន់មានជីវិតនោះទេ!
ស្រាប់តែមានការអស្ចារ្យមួយកើតឡើង។ព្រះអាទិករបានឱនទៅមុខ
ដាក់បបូរមាត់ដ៏ជាព្រះរបស់ទ្រង់ ទល់នឹងបបូរមាត់របស់ដីឥដ្ឋ
ដាក់ច្រមុះដ៏ជាព្រះរបស់ទ្រង់ទល់នឹងច្រមុះរបស់ដីឥដ្ឋ
រួចព្រះអង្គផ្លុំដង្ហើមជីវិតចូលតាមរន្ធច្រមុះដីឥដ្ឋនោះ។ដង្ហើមជីវិតរបស់
ទ្រង់ បានទម្លាយចូលទៅក្នុងសរីរាង្គកាយរបស់ដីឥដ្ឋ
និងបំផ្លាស់ប្រែទៅជាមនុស្សមានជីវិត ដោយគ្រប់ទាំងសរីរាង្គទាំងអស់
បំពេញមុខងារយ៉ាងល្អឥតខ្ចោះ
រួមជាមួយនឹងការឆ្លើយតបខាងសតិអារម្មណ៍ បញ្ញា និងវិញ្ញាណ
តាមសមត្ថភាពរបស់មនុស្ស។
គ្មានសត្វមានជីវិតណាមួយផ្សេងទៀតត្រូវបានបង្កើតតាមរបៀបនេះ
ឡើយ។

A Powerful Breath

ពាក្យដែលយកមកប្រើ
ដើម្បីពិពណ៌នាអំពីការអស្ចារ្យនេះគឺមានភាពរស់រវើកណាស់។
ភាសាហេព្រើរជាភាសាមួយ
មានលក្ខណៈច្បាស់ជាងគេក្នុងការពិពណ៌នាអំពីសកម្មភាពទាំងនេះ។
ពាក្យថា ផ្លុំខ្យល់ដង្ហើម បកប្រែមកពីភាសាហេព្រើរ យីប៉ាក
(yipakh)។វាកើតឡើងពី "ការផ្ទុះ"
នៃផ្ទៃខាងក្នុងដោយកម្លាំងខ្យល់ឥតដាច់ ចេញពីបំពង់កមក។ ដូច្នេះ
វាតំណាងឱ្យសកម្មភាពយ៉ាងរស់រវើកដូចដែលបានពិពណ៌នាមកនេះ
។

ខណៈពេល ព្រះអម្ចាស់បានឱនចុះផ្ទប់ពីលើបបូរមាត់
និងរន្ធច្រមុះរបស់រូបកាយដីឥដ្ឋនោះ
ព្រះអង្គមិនបានបញ្ចេញដង្ហើមដោយខ្សោយល្វើយនោះទេ ប៉ុន្តែ
ទ្រង់បានផ្លុំដង្ហើមចូលទៅក្នុងរូបកាយដីឥដ្ឋនោះយ៉ាងខ្លាំងវិញ
ដើម្បីឲ្យរូបកាយដីឥដ្ឋទទួលបានជីវិតពីព្រះជាម្ចាស់រស់ជាមនុស្សឡើ
ង។

ភ្លាមនោះ មនុស្សដំបូងមានលក្ខណៈត្រៃឯក រួមមានសមាសភាព
វិញ្ញាណ ព្រលឹង និងរូបកាយ។
វិញ្ញាណបានមកពីខ្យល់ដង្ហើមរបស់ព្រះជាម្ចាស់
ដែលផ្លុំបញ្ចូលក្នុងរូបកាយមនុស្សធ្វើពីដីឥដ្ឋឲ្យមានជីវិតរស់ឡើង
ដោយមានសាច់ឈាម មានជីពចរដំណើរការ ចំណែកឯព្រលឹងវិញ
កើតឡើងពីការរួមបញ្ចូលគ្នារវាងវិញ្ញាណនិងរូបកាយ
ធ្វើឲ្យមានបុគ្គលិកលក្ខណៈជាមនុស្សម្នាក់ មានភាពឯកលក្ខណៈ
និងមានសមត្ថភាពក្នុងការធ្វើការសម្រេចចិត្តបានថាខ្ញុំនឹងធ្វើ
ឬខ្ញុំនឹងមិនធ្វើ។

God's Representative

ព្រះជាម្ចាស់បានប្រគល់អំណាចឲ្យលោកអ័ដាមគ្រប់គ្រងផែនដី
និងធ្វើជាតំណាងរបស់ព្រះអង្គ
រួមជាមួយនឹងដៃគូរដែលព្រះជាម្ចាស់ប្រទានឲ្យ ។
លក្ខណៈត្រៃឯករបស់លោកអ័ដាម
តំណាងឲ្យលក្ខណៈត្រៃឯករបស់ព្រះជាម្ចាស់។
រូបរាងខាងក្រៅរបស់គាត់ ឆ្លុះបញ្ចាំងពីរូបភាពរបស់ព្រះអម្ចាស់
ដែលបានបង្កើតគាត់មក (លោកុប្បត្តិ ១:២៦-២៧)។
ទាំងលក្ខណៈខាងក្នុង
និងខាងក្រៅរបស់គាត់ជាតំណាងតែមួយគត់របស់ព្រះជាម្ចាស់ដល់សត្វមានជីវិតដទៃទៀតនៅលើផែនដី ។

លើសពីនេះទៀត លោកអ័ដាម និងនាងអេវ៉ារីករាយនឹង
សម្ព័ន្ធភាពជាមួយព្រះអម្ចាស់ជាប្រចាំ។ រាល់ពេលល្ងាចព្រះជាម្ចាស់
យាងមកចំណាយពេលជាមួយពួកគេ (លោកុប្បត្តិ ៣:៨)។ តើ
នរណាអាចដឹងបានថាព្រះជាម្ចាស់មានទំនាក់ទំនងអ្វីខ្លះជាមួយពួក
គេ? ទោះបីជាយ៉ាងណាក៏ដោយ យើងពិតជាដឹងថា ព្រះជាម្ចាស់
បានផ្តល់ឯកសិទ្ធិឲ្យលោកអ័ដាមជ្រើសរើសឈ្មោះដាក់ឲ្យសត្វមាន
ជីវិតទាំងអស់ (លោកុប្បត្តិ ២:១៩)។

មនុស្សជាតិបានកើតមានឡើង។ មារសាតាំងបោកបញ្ឆោតលោក
អ័ដាមនិងនាងអេវ៉ា ឲ្យដូរកេរមរតកដែលព្រះប្រទានឱ្យពួកគេ ជា
មួយនឹងផ្លែឈើដឹងខុសត្រូវ! ការមិនស្តាប់បង្គាប់នេះបានជះឥទ្ធិ
ពលដល់គ្រប់ផ្នែកនៃលក្ខណៈត្រៃឯករបស់លោកអ័ដាម។ វិញ្ញាណ
របស់គាត់ត្រូវបានកាត់ផ្តាច់ចេញពីព្រះជាម្ចាស់ នាំឲ្យស្លាប់ខាងឯ
វិញ្ញាណ។ ព្រលឹងរបស់គាត់ ប្រឆាំងបះបោរជាមួយព្រះអាទិករ។ រូប
កាយរបស់គាត់ ទទួលរងនូវជំងឺរោគាផ្សេងៗ ចាស់ជរា ហើយចុង
ក្រោយត្រូវស្លាប់ ។

ព្រះជាម្ចាស់បានព្រមានលោកអ័ដាម មិនឲ្យបរិភោគផ្លែពី
ដើមដឹងខុសត្រូវឡើយ ដោយថា៖ «ដ្បិតនៅថ្ងៃណាដែលឯងស៊ី
នោះនឹងត្រូវស្លាប់ជាមិនខាន» (លោកុប្បត្តិ ២:១៧)។ វិញ្ញាណ
របស់លោកអ័ដាមបានស្លាប់ភ្លាម! ប៉ុន្តែ រូបរាងកាយរបស់គាត់ មិន
ទាន់ស្លាប់ភ្លាមទេ គឺនៅរស់បានជាង៩០០ឆ្នាំទៀត។

Renewed Relationship

ការមិនស្តាប់បង្គាប់របស់លោកអ័ដាម នាំមកនូវផលវិបាក យ៉ាងធ្ងន់ធ្ងរ
ប៉ុន្តែ វាបាននាំឲ្យយើងស្គាល់ច្បាស់អំពីទិដ្ឋភាពនៃ
លក្ខណៈរបស់ព្រះជាម្ចាស់ ដែលតាំងពីមុនមកមិនបានបើកសម្តែង
ឲ្យយើងបានស្គាល់ពេញលេញឡើយ គឺជាជម្រៅនៃសេចក្តីស្រ

ឡាញ់របស់ព្រះអង្គដែលវាស់ពុំបាន។ ព្រះជាម្ចាស់មិនដែលបោះបង់ចោលលោកអ័ដាម និងកូនចៅជំនាន់ក្រោយរបស់គាត់ឡើយ។ ព្រះអង្គមានព្រះហឫទ័យចង់នាំយើងត្រឡប់មករកទ្រង់វិញ។

ព្រះជាម្ចាស់បានសម្តែងព្រះទ័យយ៉ាងច្បាស់ នៅក្នុងអត្ថបទគម្ពីរយ៉ាកុប ៤:៥ (គកស១៦) «ព្រះវិញ្ញាណដែលព្រះទ្រង់ប្រទានឲ្យមកគង់ក្នុងយើង ទ្រង់ស្រឡាញ់ដោយព្រះហឫទ័យប្រចណ្ឌ» គឺជាវិញ្ញាណ ដែលព្រះអង្គបានផ្លុំបញ្ចូលក្នុងលោកអ័ដាមនៅពេលដែលលោកត្រូវបានបង្កើត ។ អ្វីដែលមិនគួរឱ្យជឿនោះគឺថា ព្រះជាម្ចាស់នៅតែចង់មានសម្ព័ន្ធភាពផ្ទាល់ខ្លួន ដែលទ្រង់ធ្លាប់រីករាយជាមួយអ័ដាមពីមុន ។ ប៉ុន្តែ វាបានកាត់ផ្តាច់ដោយសារការបះបោររបស់លោកអ័ដាម ហើយការបះបោរនេះបន្តរហូតដល់កូនចៅជំនាន់ក្រោយរបស់លោកអ័ដាមជាប់ជានិច្ច។

លើសពីនេះទៅទៀត ព្រះជាម្ចាស់ក៏បានប្រទានមធ្យោបាយមួយដើម្បីស្តារទំនាក់ទំនងរវាងយើង និងទ្រង់ឡើងវិញ ដោយការបង់ថ្លៃដ៏ខ្ពស់បំផុត។ ព្រះជាម្ចាស់បានចាត់ព្រះយេស៊ូវ «ដ្បិតកូនមនុស្សបានមក ដើម្បីនឹងរក
ហើយជួយសង្គ្រោះដល់មនុស្សបាត់ បង់» (លូកា ១៩:១០)។ តាមរយៈយញ្ញបូជាលោះបាបរបស់ទ្រង់នៅលើឈើឆ្កាង ព្រះយេស៊ូវបានធ្វើឱ្យយើងម្នាក់ៗអាចទទួលបានការអត់ទោស និងការសម្អាតពីអំពើបាប ហើយក្លាយជាសមាជិកនៃគ្រួសាររបស់ព្រះ ។

Our True Worth

បានមានព្រះបន្ទូលជាប្រស្នា ប្រោសលោះដ៏អស្ចារ្យ
ដែលមានខ្លឹមសារយ៉ាងពីរោះបំផុត៖

> «មួយ ទៀត នគរស្ថានសួគ៌ក៏ប្រៀបដូចជាអ្នកឈ្មួញម្នាក់ ដែលរកកែវមុក្តា [គជំ ខ្សែង] យ៉ាងល្អ
> កាលណាបានឃើញ១ដែលមានដំឡៃណាស់
> នោះគាត់ទៅលក់របស់ទ្រព្យទាំងអស់
> មកទិញកែវមុក្តានោះ»។

ចំពោះខ្ញុំផ្ទាល់ នេះគឺជារូបភាពនៃការប្រោសលោះ ព្រលឹងមនុស្សម្នាក់។ ព្រះយេស៊ូវប្រៀបបាននឹងអ្នកជំនួញម្នាក់មិនមែន ជាអ្នកទេសចរណ៍ ឬក៏ជាអ្នកដើរកំសាន្តទេ ប៉ុន្តែ ជាបុរសម្នាក់ដើរទាក់ទងទិញគជំ ខ្សែងពេញមួយជីវិត ។ ហើយគាត់ប្រាកដជាដឹងអំពីតម្លៃរបស់គជំ ខ្សែងនីមួយៗ ។ គជំ ខ្សែងដែលទ្រង់ទិញបាននោះគឺ ជាព្រលឹងរបស់មនុស្សម្នាក់ៗដែលមានអ្នក និងខ្ញុំ។ ព្រលឹងនេះមានតម្លៃស្មើនឹងអ្វីទាំងអស់ដែលទ្រង់មាន អ្វីទាំងអស់ដែលជាកម្មសិទ្ធិរបស់ទ្រង់ ។

ក្នុងន័យសហសម័យ នេះជារបៀបដែលខ្ញុំមើលឃើញនៅពេលដែលឈ្មួញនោះបានទម្លាយដំណឹងដល់ប្រពន្ធគាត់ ។

“អូនសម្លាញ់! បងបានលក់ឡានរបស់យើងហើយ»។

«បងបានលក់ឡានរបស់យើងមែន! មិនអីទេ
យ៉ាងហោចណាស់យើងនៅសល់ដំបូលសម្រាប់ជ្រកដែរ»។

«អត់ទេអូន បងក៏បានលក់ទាំងផ្ទះរបស់យើងដែរ»

«បើបងចង់ ធ្វើអ្វីក៏ធ្វើទៅចុះ»?

«បងបានរកឃើញគជំ ខ្សែងស្អាតបំផុត ធ្លាប់បានឃើញពីមុនមកទេ ។ បងបានខិតខំ មួយគ្រាប់នេះអស់មួយជីវិតរបស់បងហើយ
មានតម្លៃស្មើនឹងអ្វីៗទាំងអស់ដែលបងមាន។ ចាំមើលពេលអូនឃើញវា ទើបដឹង!»

ដូច្នេះ តើពាក្យទាំងនេះមានន័យដូចម្តេចចំពោះអ្នក និង ខ្ញុំ? យើងម្នាក់ៗប្រហែលជាមើលឃើញខ្លួនឯងថា ជាគ្រាប់គជំ ដែលពុំមានតម្លៃ។

Our Redeemer

សូមចងចាំថា យើងមានតម្លៃស្មើនឹងអ្វីទាំងអស់ ដែលព្រះយេស៊ូវមានដើម្បីទិញអ្នកត្រឡប់មកព្រះអង្គវិញ។
ទោះបីព្រះអង្គជាព្រះអម្ចាស់នៃសាកលលោកទាំងមូលក៏ដោយ
ក៏ព្រះអង្គព្រមទុកវាមួយឡែក
ហើយព្រមសុគតក្នុងភាពក្រីក្រលំបាក។

> ទ្រង់ពុំមានអ្វី ជាកម្មសិទ្ធិឡើយ។ សំពត់ និងផ្ទះ
> ដែលគេបញ្ចុះសព
> ព្រះអង្គសុទ្ធតែបានមកពីការខ្ចីគេទាំងអស់។
> «ដ្បិតអ្នករាល់គ្នាបានស្គាល់ព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ
> ជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយថាទោះបើទ្រង់ជាសេដ្ឋី
> ក៏ដោយ គង់តែទ្រង់បានត្រឡប់ជាក្រ
> ដោយព្រោះអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានមានឡើង
> ដោយសារសេចក្តីកម្ររបស់ទ្រង់ » (២កូរិនថូស ៨:៩)។

ប្រហែលជាអ្នកក្រឡេកមើលទៅជីវិត ដែលពោពេញដោយការឈឺចាប់ និងមានរឿងខកចិត្តជាច្រើនដូចជា ត្រូវបានគេបដិសេធ កុមារភាពដែលខ្វះខាត និងមិនមានភាពរីករាយ អាពាហ៍ពិពាហ៍ដែលបានបញ្ចប់ដោយការលែងលះ អាជីពដែលមិនដែលចម្រុងចម្រើន ឬបានប្រើប្រាស់គ្រឿងញៀន និងសេពគ្រឿងស្រវឹង ធ្វើឲ្យខាតពេលរាប់ឆ្នាំ ។ ទាំងអតីតកាល និងអនាគតរបស់អ្នកសុទ្ធតែបង្ហាញសារដូចគ្នាថា៖ បរាជ័យ!

វាមិនមែនចំពោះព្រះយេស៊ូវទេ! ព្រះអង្គស្រឡាញ់អ្នកខ្លាំងណាស់ ហេតុនេះហើយបានជាទ្រង់លះបង់អ្វីៗទាំងអស់ដើម្បីប្រោសលោះអ្នក ។ សូមនិយាយតាមខ្ញុំនូវពាក្យសម្តីដ៏ពិរោះមានន័យរបស់សាវកប៉ុល ហើយឱ្យពាក្យទាំងអស់ក្លាយទៅជាពាក្យរបស់អ្នក៖ “ទ្រង់ស្រឡាញ់ខ្ញុំ ក៏បានប្រគល់ព្រះអង្គទ្រង់ជំនួសខ្ញុំហើយ» ។ សូមនិយាយម្តងទៀត “ទ្រង់ស្រឡាញ់ខ្ញុំ ក៏បានប្រគល់ព្រះអង្គទ្រង់ជំនួសខ្ញុំហើយ»
ម្តងទៀតថា “ទ្រង់ស្រឡាញ់ខ្ញុំ
ក៏បានប្រគល់ព្រះអង្គទ្រង់ជំនួសខ្ញុំហើយ» (កាឡាទី ២:២០)។
ឥឡូវនេះ សូមលោកអ្នកមើលមកខ្លួនឯក ដូចជាគជមួយគ្រាប់ដែលស្ថិតនៅក្នុងព្រះហស្ត
ដែលមានស្នាមដែកគោលរបស់ព្រះយេស៊ូវ។

ចូរស្តាប់ព្រះអង្គមានព្រះបន្ទូលមកកាន់អ្នកថា
“អ្នកស្រស់ស្អាតខ្លាំងណាស! ខ្ញុំបានចំណាយទាំងអស់

ដែលខ្ញុំមានដើម្បីទិញយកអ្នក ហើយខ្ញុំមិនសោកស្តាយទេ។
ឥឡូវនេះអ្នកជារបស់ខ្ញុំជារៀងរហូត!»។

អ្នកមិនអាចធ្វើអ្វីដើម្បីទទួលបានសេចក្តីស្រឡាញ់ និងការទទួលយកនេះទេ។ អ្នកមិនអាចផ្លាស់ប្តូរ ឬធ្វើឱ្យខ្លួនអ្នកបានល្អគ្រប់គ្រាន់នោះទេ។ អ្វីដែលអ្នកអាចធ្វើបានគឺទទួលយកអ្វីដែលព្រះយេស៊ូវបានធ្វើសម្រាប់អ្នក ហើយអរព្រះគុណទ្រង់!

អ្នកជាកម្មសិទ្ធិរបស់ទ្រង់ជារៀងរហូត!

: TL-L120-100-KHM
: 26 Mar 2026
: derekprince.com/km/resources

